**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាអភិបូជាបុណ្យរោយផេះនៅផ្សារតូច**
**ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨**
*យើងជាទូតរបស់ព្រះគ្រីស្ត*

អត្ថបទទី១៖ យអ ២,១២-១៨
អត្ថបទទី២៖ ២ករ ៥,២០-៦,២
ដំណឹងល្អ៖ មថ ៦,១-៦.១៦-១៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្តាប់នៅក្នុងគម្ពីរ ព្រះជាម្ចាស់មិនណែនាំឲ្យយើងបង្ហាញមុខនៅពេលយើងជួយអ្នកដទៃ នៅពេលយើងអធិដ្ឋាន នៅពេលយើងតមអាហារ។ អ្វីៗដែលយើងធ្វើយើងធ្វើនៅក្នុងទីសម្ងាត់នៃដួងចិត្តរបស់យើង។ ថ្ងៃនេះដែលយើងចូលនៅក្នុងរដូវ៤០ថ្ងៃជាពេលវេលាមួយ ដើម្បីឲ្យយើងរៀងៗខ្លួនចាប់ផ្តើមចូលយ៉ាងជ្រៅនៅក្នុងជីវិតផ្ទាល់ខ្លួនដោយកែប្រែចិត្តគំនិត និងជឿលើដំណឹងល្អចុះ។ អត្ថបទទីពីរ "**ដូច្នេះយើងជាទូតរបស់ព្រះគ្រីស្ត គឺដូចព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនបងប្អូនដោយសារយើងដែរ**" យើងជាទូតរបស់ព្រះគ្រីស្ត នេះជាបេសកកម្មសម្រាប់យើងដែលជាគ្រីស្តបរិស័ទ។ រដូច៤០ថ្ងៃជាពេលវេលាមួយយ៉ាងពិសេស ដើម្បីឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង ដើម្បីកែប្រែចិត្តកំនិត ដើម្បីប្រកាសម្តងទៀតខ្ញុំជឿលើព្រះជាម្ចាស់ ដើម្បីបំពេញតួនាទីរបស់យើងជាទូតរបស់ព្រះគ្រីស្ត។

ឆ្នាំនេះនៅក្នុងសារលិខិតរបស់សម្តេចប៉ាប សម្រាប់រដូវ៤០ថ្ងៃ មានចំណងជើងថា "**ដោយសារអំពើទុច្ចរិត ដោយសារអំពើអាក្រក់ដែលមនុស្សបានប្រព្រឹត្ត ណែនាំឲ្យធម៌មេត្តាករុណាថយទៅៗនៅក្នុងពិភពលោកទាំងមូល**"។ នៅក្នុងពិភពលោករបស់យើងមានអំពើទុច្ចរិតពិតមែន មានអំពើអយុត្តិធម៌ពិតមែន មានអំពើអាក្រក់ពិតមែន គ្រប់អំពើឃោរឃៅនេះណែនាំឲ្យចិត្តមេត្តាករុណារបស់មនុស្សថយទៅៗ។ សម្តេចប៉ាប ណែនាំឲ្យព្រះសហគមន៍របស់យើង ចូលនៅក្នុងរបៀបថ្មីដើម្បីសួរ តើមានអ្វីខ្លះដែលណែនាំឲ្យសេចក្តីស្រឡាញ់របស់យើងទៅជាសេចក្តីស្រឡាញ់ត្រជាក់ ដែលណែនាំឲ្យបងប្អូនឯទៀតៗមើលមិនឃើញអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ដោយសារ របៀបយើងទៅជាឧបសគ្គរបស់សេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ មិនអាចទៅដល់បងប្អូនឯទៀតៗ។ នៅក្នុងឆ្នាំនេះ ឲ្យយើងយកចិត្តទុកដាក់ដើម្បីគិត **តើមានអ្វីខ្លះនៅក្នុងជីវិតរបស់ខ្ញុំ**

**ផ្ទាល់ ដែលណែនាំឲ្យធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ មិនអាចភ្លឺដល់បងប្អូនឯទៀតៗ យ៉ាងពិតប្រាកដ?** សម្តេចប៉ាបបានសួរថា **តើយើងត្រូវការធ្វើអ្វីខ្លះដើម្បីទៅជាមនុស្សថ្មី? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទៅជាសាក្សីនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ? តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទៅជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់?** យើងបង្ហាញសេចក្តីស្រឡាញ់ដែលចេញពីដួងចិត្តរបស់យើង ឲ្យយើងទៅជាផ្កាកូលាបមួយយ៉ាងពិសេសសម្រាប់បងប្អូនឯទៀតៗនៅក្នុងសង្គម។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងធ្វើយ៉ាងណាសដើម្បីឲ្យសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ ដោយបើកភ្នែកនិងដួងចិត្តរបស់យើងជានិច្ច។ សម្តេចប៉ាប បានអញ្ជើញយើងក្នុងរដូវ៤០ថ្ងៃនេះឲ្យយើងយកពេលវេលាដើម្បីអធិដ្ឋានដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

សម្តេចប៉ាប បានណែនាំឲ្យយើងយកចិត្តទុកដាក់ចែករំលែកទ្រព្យសម្បត្តិដែលយើងមាន មិនមែនតែសេចក្តីស្រឡាញ់ យើងធ្វើយ៉ាងណាដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតដែលចេះចែករំលែកដល់បងប្អូនដែលកំពុងខ្វះខាត។ ឲ្យយើងចេះចែករំលែកដល់បងប្អូនឯទៀតៗ ឲ្យទៅជាធម្មជាតិរបស់យើង ឲ្យទៅជាឥរិយាបថរបស់យើង ឲ្យទៅជាចរិតផ្ទាល់របស់យើង។ ពេលយើងឃើញបងប្អូនដៃឡកំពុងមានបញ្ហា យើងធ្វើយ៉ាងណាដើម្បីចូលនៅក្នុងចិត្តរបស់គេ ដើម្បីដឹងអំពីទុក្ខលំបាករបស់គេ ដើម្បីទៅជាសញ្ញាសម្គាល់នៃឧបការគុណរបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ស្រឡាញ់យើង ព្រះអង្គត្រូវការយើងដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗ។ យើងធ្វើយ៉ាងណា ដើម្បីឲ្យជីវិតរបស់យើងមិនមែនជីវិតលោភលន់ ប៉ុន្តែជាជីវិតសម្រាប់បងប្អូនឯទៀតៗ។ យើងអាចរកឃើញសុភមង្គល និងសេចក្តីសុខចាប់ពីពេលយើងយកចិត្តទុកដាក់បើកចិត្តគំនិតដល់បងប្អូនឯទៀត ដោយសម្តែងសេចក្តីស្រឡាញ់និងធម៌មេត្តាករុណា ចិត្តអាណិតមេត្តាយ៉ាងពិតប្រាកដ។

សម្តេចប៉ាបជម្រុញយើង ឲ្យយើងយកចិត្តទុកដាក់ដើម្បីតមអាហារ យើងយកពេលហ្នឹងដើម្បីអធិដ្ឋានថែមទៀត ដើម្បីយកចិត្តទុកដាក់ជាមួយបងប្អូនថែមទៀត និងប្រមូលលុយខ្លះៗជួយអ្នកដទៃថែមទៀត។ តមអាហារ ជាពេលវេលាមួយដើម្បីរស់នៅក្នុងខ្លួនរបស់យើង ឲ្យយើងយល់តើយើងត្រូវការអ្វីខ្លះដើម្បីរស់នៅ? ឲ្យយើងគិតដល់ពេលវេលាហ្នឹងដើម្បីជួយដល់បងប្អូនឯទៀតៗ នៅក្នុងការអធិដ្ឋានជាមួយព្រះជាម្ចាស់។ កម្លាំងដែលយើងអាចប្រមូល ដើម្បីទៅជាសាក្សី និងដើម្បីអនុវត្តអ្វីដែលសន្តប៉ូលបានអញ្ជើញយើង។ យើងជាទូតរបស់ព្រះគ្រីស្ត ដើម្បីប្រកាសដំណឹងល្អ បន្តិចទៀតយើងធ្វើបុណ្យពោយផេះ យើងកើតពីធូលី យើងទីជាធូលីសារជាថ្មី យើងជាមនុស្សដែលប្រព្រឹត្តអំពើបាប ប៉ុន្តែព្រះជា

ម្ចាស់បើកផ្លូវ ដើម្បីឲ្យយើងកែប្រែចិត្តគំនិតឲ្យយើងធ្វើជាមនុស្សថ្មី ដោយសារយើងជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យយើងធ្វើដំណើរជាមួយព្រះយេស៊ូ ដែលសោយទិវង្គត និងដែលមានព្រះជន្មរស់ឡើងវិញ។ អាម៉ែន៕